**មាត្រា១ .** ត្រូវបានបំពាក់ មេដាយ **មុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា** ជូន ឯកឧត្តម អស់លោក ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចជួយប្រជារាស្ត្រ ដែលរងគ្រោះដោយសារគ្រោះរាំងស្ងួត និង ទឹកជំនន់ ឆ្នាំ ២០០២ ដូចមានរាយនាម ខាងក្រោម :

១-ឯកឧត្តម **ចន្ទ័ សុខអ៊ីវ** រដ្ឋលេខាធិការ ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

២-ឯកឧត្តម **ម៉ម ប៊ុនហេង** រដ្ឋលេខាធិការ ក្រសួង សុខាភិបាល

៣-ឯកឧត្តម **សួស គង់** អនុរដ្ឋលេខាធិការ ក្រសួង អភិវឌ្ឍន៍ជនបទ

៤-ឯកឧត្តម **អ៊ិត ណូឌី** អនុរដ្ឋលេខាធិការ ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

៥-ឯកឧត្តម **ហ៊ិន ណេង** ប្រធាន គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត ស្វាយរៀង

៦-ឯកឧត្តម **ឡូយ សុផាត** ប្រធាន គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត ក្រចេះ

៧-ឯកឧត្តម **កែប ជុតិមា** ប្រធាន គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត តាកែវ

៨-ឯកឧត្តម **ឆេព ននរី** ប្រធាន គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត កណ្ដាល

៩-ឯកឧត្តម **ជៀង អំ** ប្រធាន គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត កំពង់ចាម

១០-ឯកឧត្តម **ហ៊ឹម ស្មៀត** ទីប្រឹក្សា សម្តេចនាយករដ្ឋមន្ត្រី

១១-ឯកឧត្តម **ពៅ សាមី** អគ្គលេខាធិការ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

១២-ឯកឧត្តម **អ៊ុក ដាមរី** អនុប្រធានទី១ កាកបាទក្រហមកម្ពុជា

១៣-ឧត្តមសេនីយ៍ឯក **មល់ រឿប** ទីប្រឹក្សា សម្តេចនាយករដ្ឋមន្ត្រី

១៤-ឧត្តមសេនីយ៍ទោ **យូ ស៊ុនឡុង** ទីប្រឹក្សា សម្តេចនាយករដ្ឋមន្ត្រី

១៥-ឧត្តមសេនីយ៍ឯក **ជា តារា** នាយករងសេនាធិការចំរុះ មេបញ្ជាការ

១៦-ឧត្តមសេនីយ៍ឯក **អ៊ុង សំខាន់** មេបញ្ជាការ កងទ័ពជើងទឹក

១៧-ឧត្តមសេនីយ៍ឯក **សៅ សុខា** មេបញ្ជាការ កងរាជអាវុធហត្ថលើផ្ទៃប្រទេស

១៨-ឧត្តមសេនីយ៍ឯក **ផាន់ ខួន** អគ្គលេខាធិការរងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

១៩-ឧត្តមសេនីយ៍ទោ **ជៀង សុវណ្ណថា** មេបញ្ជាការ យោធភូមិភាគ ២

២០-ឧត្តមសេនីយ៍ទោ **ហ៊ុយ ពិសិដ្ឋ** មេបញ្ជាការ កងឯកភាពអង្គរក្ស សម្តេចនាយករដ្ឋមន្ត្រី

២១-ឯកឧត្តម **សេង ឡេង** ជំនួយការ សម្តេចនាយករដ្ឋមន្ត្រី

២២-ឯកឧត្តម **ហេង តៃគ្រី** ទីប្រឹក្សា សម្តេចនាយករដ្ឋមន្ត្រី

២៣-លោក **ហង្ស សាមឿន** អគ្គលេខាធិការរង គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

២៤-លោក **ប្អូន លឹមហេង** ប្រធាន នាយកដ្ឋានផ្គត់ផ្គង់ហិរញ្ញកិច្ច ទីស្តីការគណៈរដ្ឋមន្ត្រី

២៥-លោក **អ៊ុយ សំអាត** ប្រធាននាយកដ្ឋាន គ្រប់គ្រងគ្រោះមហន្តរាយកាកបាទក្រហមកម្ពុជា

**មាត្រា២ .** រដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការ គណៈរដ្ឋមន្ត្រី និង គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ , ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>កន្លែងទទួល</u>

-ក្រសួង ព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា

- អគ្គលេខាធិការដ្ឋាន រដ្ឋសភា

-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី ✓

-ដូចក្នុងមាត្រា១ និង មាត្រា ២

-រាជកិច្ច

-កាលប្បវត្តិ -ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៥៤៦ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

&&&&&

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ / ០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយសេរីវឌ្ឍស្ថាបនាជាតិ** ជូនសប្បុរសជន ០៤ គ្រួសារ ដែលបានបរិច្ចាគធនធាន ជួយកសាងអគារសិក្សា ០១ ខ្នង នៅសាលាបឋមសិក្សា ហ៊ុន សែន ចំពុះក្អែក ស្រុកកៀនស្វាយ ខេត្តកណ្តាល ដូចមានរាយនាមខាងក្រោម ÷

១-លោកស្រី **តាំង វិញឡេង** និង ប្តី ថវិកាចំនួន ៤.០០០ USD
២-លោក **នួន ពូចម៉ីង** និង អ្នកស្រី ថវិកាចំនួន ៤.០០០ USD
៣-លោកយាយ **តាំង ឆៃគីម** និង បុត្រ ថវិកាចំនួន ៤.០០០ USD
៤-លោកយាយ **តាំង គីមលី** និង ក្រុមគ្រួសារ ថវិកាចំនួន ៤.០០០ USD

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ :...៤១...សសរ

# សេចក្តីសំរេច

## ស្តីពីការផ្ទេរសិទ្ធិ នៃរាជរដ្ឋាភិបាលកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

**សំ រេ ច**

**ប្រការ ១ :** ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាលកម្ពុជា ជំនួសសម្តេចនាយករដ្ឋមន្ត្រី ដែលត្រូវអញ្ជើញទៅចូលរួមសន្និសីទអន្តរជាតិលើកទី ២ នៃគណបក្សនយោបាយនៅអាស៊ី នៅទីក្រុងបាងកក ចាប់ពីថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០០២ រហូតដល់សម្តេចនាយករដ្ឋមន្ត្រី អញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

**ប្រការ ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន នៃរាជរដ្ឋាភិបាល អភិបាលខេត្ត-ក្រុង និងឯកឧត្តម ស ខេង ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០២*

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

ចម្លងជូន :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ២ (ដើម្បីអនុវត្ត)*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៥៧ ស.សរ

# សេចក្តីសម្រេច

## ស្តីពីការផ្ទេរសិទ្ធ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ ១ :** ត្រូវបានផ្ទេរសិទ្ធជូនឯកឧត្តម **ឆាយ ថន** រដ្ឋមន្ត្រីក្រសួងផែនការ ជារដ្ឋមន្ត្រីស្តីទីក្រសួងពាណិជ្ជកម្ម ជំនួសឯកឧត្តម **ចម ប្រសិទ្ធ** ដែលត្រូវអញ្ជើញទៅបំពេញបេសកកម្មនៅបរទេស ចាប់ពីថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ២០០២ រហូតដល់ថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០០២ ។

**ប្រការ ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត-ក្រុង និង ឯកឧត្តម **ឆាយ ថន** ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ២ ( ដើម្បីអនុវត្ត )
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ៧៥៥ សហវ (ប្រក)

រាជធានីភ្នំពេញ , ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០០២

**ប្រកាស**

**ស្តីពី**

**ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីធ្វើការវាយតម្លៃលើ**

**ផលប៉ះពាល់ដល់សំណង់ផ្ទះសម្បែង ដីធ្លី ប្រជារាស្ត្រ**

**ក្នុងគំរោងការកែលំអទីរួមខេត្ត-ក្រុង**

❀ ❀ ❀

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ។
- បានឃើញចំណារឯកភាពរបស់សម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០២ លើសំណើរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លេខ ២៧៦៣ សហវ វស ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០២ ។

**ស ំ រ េ ច**

**ប្រការ ១ :** បង្កើតគណៈកម្មការអន្តរក្រសួងមួយ ដើម្បីធ្វើការវាយតម្លៃលើផលប៉ះពាល់ដល់ សំណង់ ផ្ទះសម្បែង ដីធ្លី ប្រជារាស្ត្រ ក្នុងគំរោងការកែលំអទីរួមខេត្ត-ក្រុង ។

**ប្រការ ២ :** គណៈកម្មការអន្តរក្រសួងនេះមានសមាសភាពដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម **ញាណ ឡេង** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ប្រធាន |
| ២. | លោក **ទ្រាក់ ស៊ីហារ៉ា** | អភិបាលរងទី ២ ក្រុងព្រះសីហនុ | សមាជិក |

៣. លោក **សៅ ចរម** អនុប្រធាននាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការ នៃ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជំនួយការ

៤. លោក **ខៀវ ពិសិដ្ឋ** ជានាយកគំរោង អភិវឌ្ឍន៍ទីរួមខេត្ត-ក្រុង ក្រសួងសាធារណការ និង ដឹកជញ្ជូន សមាជិក

៥. លោក **ឈ៊ូ គុណឈុឡេន** ប្រធានការិយាល័យធនាគារអភិវឌ្ឍន៍អាស៊ី នាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការ នៃ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជំនួយការ

៦. លោក **ជូ ចាន់នី** មន្ត្រីគំរោងការិយាល័យធនាគារអភិវឌ្ឍន៍អាស៊ី នាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការ នៃ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជំនួយការ

**ប្រការ ៣ :** គណៈកម្មការអន្តរក្រសួង មានភារកិច្ចចុះទៅពិនិត្យដល់ទីកន្លែង ធ្វើស្ថិតិលើផលប៉ះពាល់ដល់សំណង់ ផ្ទះសម្បែង ដីធ្លី ប្រជារាស្ត្រ ក្នុងគំរោងការកែលំអទីរួមខេត្ត-ក្រុង រួចធ្វើការវាយតំម្លៃឱ្យបានសមស្រប ដើម្បីមានមូលដ្ឋានដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និង សំរេចនូវថវិកាមួយចំនួនជាគោលនយោបាយជូនដល់ប្រជារាស្ត្រវិញ ។

**ប្រការ ៤ :** គណៈកម្មការនេះ មានសិទ្ធិបង្កើតអង្គភាពរៀបចំការតាំងទីលំនៅឡើងវិញ ជាសេនាធិការផ្ទាល់ និង មានសិទ្ធិប្រើប្រាស់ការិយាល័យគោលនយោបាយ និង ផែនការ នៅនាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការ នៃ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាលេខាធិការដ្ឋាន សំរាប់បំពេញការងារប្រចាំថ្ងៃ ។

**ប្រការ ៥ :** ក្រសួងសាធារណការ និង ដឹកជញ្ជូន , សាលាក្រុងព្រះសីហនុ , នាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការ , នាយកដ្ឋានទ្រព្យរដ្ឋ នៃ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានភារកិច្ចអនុវត្តប្រកាសនេះ ចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

ចំលងជូន :

-ខុទ្ទកាល័យព្រះមហាក្សត្រ

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ដូចប្រការ ៥

-ឯកសារកាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ [illegible] សហវ.[illegible]

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ២០០២

## ប្រកាសអន្តរក្រសួង
## ស្តីពី
## ការបង្កើត និង កែតម្រូវប្រាក់ការបើកផ្តល់ សំរាប់បើក បៀវត្ស និង ប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ ជូនមន្ត្រីរាជការ នៅក្រសួងសាធារណការ និង ដឹកជញ្ជូន

### ទេសរដ្ឋមន្ត្រី-រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
### រដ្ឋមន្ត្រី ក្រសួងសាធារណការ និង ដឹកជញ្ជូន

-បានឃើញ រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញ ព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយ ព្រះរាជក្រមលេខ ១១/នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវកែប្រែដោយច្បាប់ ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩

-បានឃើញ ព្រះរាជក្រមលេខ នស/រកម/១២០១/១៥ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២

-បានឃើញ អនុក្រឹត្យលេខ ៨២ អនក្រ-បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ

-បានឃើញ ប្រកាសលេខ ០០៤ សហវ.មប្រក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ជាទូទៅ នៃ គណនេយ្យសាធារណៈ

-បានឃើញ លិខិតលេខ ១១៥ សហវ.ម ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ជាទូទៅ នៃគណនេយ្យ សាធារណៈ ។

-បានឃើញ តម្រូវការចាំបាច់នៃការងារសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បច្ចុប្បន្ន ។

## សម្រេច

**ប្រការ ១** : ប្រាក់បៀវត្សមន្ត្រីរាជការ និង ប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ ត្រូវបើកផ្តល់តាមរយៈ "ភ្នាក់ងារបើកផ្តល់" ។

**ប្រការ ២** : ត្រូវបានតែងតាំង :

-អ្នកស្រី **ឃាង់ សាព** បុគ្គលិកការិយាល័យហិរញ្ញកិច្ច-ថវិកា នៃនាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ ជាភ្នាក់ងារបើកផ្តល់ ។

-អ្នកស្រី **សុខ ខេមរា** ជាភ្នាក់ងារបើកផ្តល់ជំនួស ។

**ប្រការ ៣**: អ្នកស្រី **ឃាង់ សាព** និង អ្នកស្រី **សុខ ខេមរា** ត្រូវបានអនុញ្ញាតឱ្យបើកគណនីប្រាក់បញ្ញើ នៅធនាគារជាតិ ដើម្បីទទួលមូលនិធិ សំរាប់យកទៅបើកបៀវត្ស និងប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និងវប្បធម៌ ជូនមន្ត្រីរាជការ ។

**ប្រការ ៤**: របៀបបទនៃការអនុវត្តន៍បើកផ្តល់បៀវត្ស និង ប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ នឹងត្រូវកំណត់ដោយសេចក្តីណែនាំជាក្រោយ ។

**ប្រការ ៥**: ភ្នាក់ងារបើកផ្តល់ត្រូវ ទទួលខុសត្រូវផ្ទាល់ចំពោះ ប្រាក់កាស និង មូលនិធិដែលបានទទួល ដើម្បីយកទៅធ្វើការបើកផ្តល់ជូនមន្ត្រីរាជការ ។

**ប្រការ ៦**: សេចក្តីសំរេចទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៧**: អគ្គលេខាធិការ, នាយកខុទ្ទកាល័យ, ប្រធានធនាគារជាតិ, ប្រធាននាយកដ្ឋានថវិកានីយកម្ម និង ហិរញ្ញវត្ថុ, ប្រធាននាយកដ្ឋាន និង អង្គភាពពាក់ព័ន្ធក្រោមឱវាទ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងសាធារណការ និង ដឹកជញ្ជូន ព្រមទាំង អ្នកស្រី **ឃាង់ សាព** និង អ្នកស្រី **សុខ ខេមរា** ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

**រដ្ឋមន្ត្រី ក្រសួងសាធារណការ និង ដឹកជញ្ជូន**

**ឃី តាំងលីម**

កន្លែងទទួល :
-ទីស្តីការគណៈរដ្ឋមន្ត្រី
"ដើម្បីជូនជ្រាប"
-ដូចប្រការ ៧
"ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**KINGDOM OF CAMBODIA**

Nation - Religion - King

**ក្រសួងពាណិជ្ជកម្ម**

**Ministry of Commerce**

No. ២៦១ MoC / M 2002

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ២០០២

# ប្រកាស

## ស្តីពី ស្ថានភាពរោងចក្រ SHELBY CAMBODIA CO., LTD. នៅកម្ពុជា

*****

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យ លេខ ៥៤ អនក្របក ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ ក្រសួងពាណិជ្ជកម្ម
- បានឃើញការចាំបាច់របស់ក្រសួង

## សំរេច

**ប្រការ ១ :** ចាត់ទុករោងចក្រកាត់ដេរផលិតស្រោមដៃ **SHELBY CAMBODIA CO., LTD.** ដែលលែងមានដំណើរការ ហើយកម្មករត្រូវបានបញ្ឈប់ពីការងារ ថាបាន **បិទទ្វារជាស្ថាពរ** ។ រោងចក្រកាត់ដេរសំលៀកបំពាក់នេះនឹងត្រូវលប់ចេញពីតារាង GSP នៃអ្នកមានសិទ្ធនាំចេញនៅនាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ។ ការចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្មនឹងត្រូវ

ឆ្លូតពណ៌ក្រហម និង ចារថាបានបិទទ្វារ ។

**ប្រការ ២ :** ការស៊ើបអង្កេតបន្ថែមទៀតនឹងត្រូវធ្វើឡើងដោយ នាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម , នាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស , នាយកដ្ឋាននិតិកម្ម ទាក់ទិនបំណុល និង ការទទួលខុសត្រូវផ្សេងៗនៃរោងចក្រដែលមានឈ្មោះខាងលើចំពោះតតីយជននៅកម្ពុជា ព្រមទាំងបំណុលរបស់គេចំពោះច្បាប់ និង បទបញ្ញត្តិកម្ពុជា ។

**ប្រការ ៣ :** នាយកខុទ្ទកាល័យ , អគ្គនាយកបច្ចេកទេស , ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម , ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស , ប្រធាននាយកដ្ឋាននិតិកម្ម និង រោងចក្រដែលមានឈ្មោះក្នុងប្រការ ១ ត្រូវអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**ចម ប្រសិទ្ធ**

**ចម្លងជូន :**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ខុទ្ទកាល័យទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល
- ក្រសួងសង្គមកិច្ច-ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវៈនិតិសម្បទា
- ស្ថានរាជទូតកម្ពុជាប្រចាំទីក្រុងប៉ារីស
- ស្ថានរាជទូតកម្ពុជាប្រចាំទីក្រុងវ៉ាស៊ីនតោនឌីស៊ី
- ស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា
- គណៈប្រតិភូសហគមន៍អឺរ៉ុបប្រចាំទីក្រុងបាងកក
- គណៈប្រតិភូសហគមន៍អឺរ៉ុបប្រចាំទីក្រុងភ្នំពេញ
- សមាគមកាត់ដេរសំលៀកបំពាក់នៅកម្ពុជា
- ឯកសារ-កាលប្បវត្តិ



Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 ( Kingdom of Cambodia )
Minister' s Mobile Phone (855-12) 821888 Facsimile: (855-23) 213288
Staff's Mobile Phones: (855-12) 818883 / 881223 Facsimile: (855-23) 426396

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**KINGDOM OF CAMBODIA**

Nation - Religion - King

**ក្រសួងពាណិជ្ជកម្ម**

**Ministry of Commerce**

No. ៥៥៤ MoC / M 2002

រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ ២០០២

# ប្រកាស

## ស្តីពី : ការផ្តល់វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ (Certificate of Origin) ជូនអង្គការក្រៅរដ្ឋាភិបាល (NGOs)

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យ លេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ ក្រសួងពាណិជ្ជកម្ម
- ក្នុងគោលបំណងបង្កើនសន្ទុះនាំចេញផលិតផលក្នុងស្រុក និង ដើម្បីជួយសំរួលបែបបទនាំចេញផលិតផលសិប្បកម្មផ្សេងៗ ធ្វើអំពីសូត្រ . អំបោះ . ដែក . ផ្តៅ . កំប្លោក . ស្លឹកត្នោត . គ្រឿងចម្លាក់សម័យទំនើប . វត្ថុប្រើប្រាស់បន្ទាប់បន្សំ ។ល។ ឱ្យបានឆាប់រហ័ស

## សំរេច

**ប្រការ ១ :** ដើម្បីអោយអង្គការក្រៅរដ្ឋាភិបាលមានសិទ្ធ ទទួលបានវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញពីក្រសួងពាណិជ្ជកម្ម សំរាប់នាំទំនិញសិប្បកម្មរបស់ខ្លួនទៅបរទេសបាន អង្គការក្រៅរដ្ឋាភិបាល (NGOs) ត្រូវបង្កើតក្រុមហ៊ុនមួយជាលក្ខណ:សហគ្រាសឯកបុគ្គល ទទួលខុសត្រូវមានកំរិត ដោយប្រើប្រាស់ដើមទុនបានមកពីអង្គការក្រៅរដ្ឋាភិបាល រីឯប្រាក់ចំណេញត្រូវបានបង្វិលទៅអង្គការក្រៅរដ្ឋាភិបាលនោះទាំងស្រុងវិញ ។

**ប្រការ ២ :** បន្ទាប់ពីបានបង្កើតក្រុមហ៊ុននៅនាយកដ្ឋាននិតិកម្មរួចហើយ អង្គការក្រៅរដ្ឋាភិបាលត្រូវចុះបញ្ជីនៅនាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ដើម្បីទទួលបានសិទ្ធនាំចេញតាមរយៈប្រព័ន្ធ MFN/GSP (លើកលែងផលិតផលជាប់កូតា) ។

**ប្រការ ៣ :** ការចេញវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញនេះ (C/O) ត្រូវបានលើកទឹកចិត្តជូនដោយមិនមានបង់កំរៃ ឬ សោហ៊ុយរដ្ឋបាលអ្វីឡើយ ក្នុងករណីផលិតផលនាំចេញមិនជាប់កូតា ។

**ប្រការ ៤ :** នាយកខុទ្ទកាល័យ , អគ្គនាយកបច្ចេកទេស , អគ្គនាយករដ្ឋបាល និង ហិរញ្ញវត្ថុ , ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម , ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស , ប្រធាននាយកដ្ឋាននិតិកម្ម , ប្រធាននាយកដ្ឋានកាំកុងត្រូល , ប្រធាននាយកដ្ឋានរដ្ឋបាល ត្រូវអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធិភាព ។

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចម ប្រសិទ្ធ

**ចម្លងជូន :**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល
- ក្រសួងសង្គមកិច្ច-ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវៈនិតិសម្បទា
- អង្គការក្រៅរដ្ឋាភិបាល
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**KINGDOM OF CAMBODIA**

Nation - Religion - King

**ក្រសួងពាណិជ្ជកម្ម**

**Ministry of Commerce**

No.២៦៧ MoC / M 2002

រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ ២០០២

# ប្រកាស

## ស្តីពី : ការអនុវត្តប្រព័ន្ធសហវិមជ្ឈការរបស់ក្រសួងពាណិជ្ជកម្ម នៅតាមបណ្តាខេត្ត-ក្រុង សំរាប់គ្រប់គ្រងរោងចក្រដែលនៅឆ្ងាយ

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្ត ទៅរបស់ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យ លេខ ៥៤ អនក្របក ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្ត ទៅរបស់ ក្រសួងពាណិជ្ជកម្ម
- យោងស្មារតីអង្គប្រជុំ " ច្រកចេញ-ចូលតែមួយ " នៃ ក.អ."គ.វ.ក" នាថ្ងៃទី២២ ខែសីហា ឆ្នាំ២០០២ និងចំណារសម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០២
- យោងស្មារតីអង្គប្រជុំអន្តរក្រសួង នាថ្ងៃទី០៤ ខែតុលា ឆ្នាំ២០០២
- យោងតាមការចាំបាច់របស់ក្រសួង

## សំរេច

**ប្រការ ១ :** ចាប់តាំងពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៣ តទៅ មន្ទីរពាណិជ្ជកម្មខេត្ត-ក្រុងដែលនៅឆ្ងាយ ចំនួន ០៤ គឺ ខេត្តស្វាយរៀង , ខេត្ត កំពង់ចាម , ខេត្តកំពង់ឆ្នាំង និង ក្រុងព្រះសីហនុ ត្រូវសហការណ៍ជាមួយមន្ត្រីជំនាញរបស់ក្រសួងដែលបានចាត់តាំងចំនួន ០៤ នាក់ ក្នុងមួយខេត្ត-ក្រុង ដើម្បីអនុវត្តប្រព័ន្ធសហវិមជ្ឈការ សំរាប់គ្រប់គ្រងរោងចក្រ ។

មន្ត្រីជំនាញនេះមានភារកិច្ចជួយបណ្តុះបណ្តាល និង ណែនាំអំពីគោលការណ៍ច្បាប់ប្រភពដើមទំនិញ (Rules of Origin) និង ច្បាប់ផ្សេងៗទៀតទាក់ទងនឹងការនាំចេញ ។

**ប្រការ ២ :** ក្រុមហ៊ុន ឬរោងចក្រអាចដាក់ពាក្យសុំរបស់ខ្លួននៅមន្ទីរពាណិជ្ជកម្មខេត្ត-ក្រុង ដោយផ្ទាល់ ហើយទទួលយកវិញនៅទីនោះដដែល ក្នុងរយៈពេល ៤៨ ម៉ោង ស្មើនឹង ០២ ថ្ងៃធ្វើការ ចំពោះឯកសារត្រឹមត្រូវ និង គ្រប់គ្រាន់ ។

**ប្រការ ៣ :** មន្ទីរពាណិជ្ជកម្មខេត្ត-ក្រុង មានភារកិច្ចរៀបចំឯកសារនៃការត្រួតពិនិត្យ ផលិតកម្មរោងចក្រ , បំរែបំរួលផលិតកម្ម , របាយការណ៍ត្រួតពិនិត្យទំនិញ និង ស្ថានការណ៍របស់រោងចក្រ ដោយបញ្ជូនឡើងមកក្រសួង តាមរយៈនាយកដ្ឋានជំនាញ ។

**ប្រការ ៤ :** ក្រៅអំពីខេត្ត-ក្រុង ដូចបានកំណត់ខាងលើ គឺនៅរក្សាស្ថានភាពការងារដដែល រហូតដល់ខេត្ត-ក្រុងឆ្ងាយៗទាំងឡាយនោះមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីដំណើរការប្រព័ន្ធសហវិមជ្ឈការនេះ ឱ្យមានប្រសិទ្ធភាព ។

**ប្រការ ៥ :** ចំពោះនិតិវិធីនៃការបញ្ជូនឯកសារ-ពតិមានផ្សេងៗ នាយកដ្ឋានជំនាញ និងមន្ទីរពាណិជ្ជកម្ម ខេត្ត-ក្រុង ត្រូវពិនិត្យដោះស្រាយឱ្យបានល្អប្រសើរគត់ហ្មត់ រក្សាការសម្ងាត់ទៅតាមលទ្ធភាព ដែលអាចធ្វើទៅបាន ដើម្បីធានាជៀសវាងសនាអំពីអត្ថប្រយោជន៍ MFN/GSP សំរាប់កម្ពុជា និង ចៀសវាងការ រាំងស្ទះ ដោយប្រការណាមួយ ប៉ះពាល់ដល់ការនាំចេញរបស់ក្រុមហ៊ុន ឬ រោងចក្រ ។

**ប្រការ ៦ :** កែសំរួលនិតិវិធីមួយចំនួននៃការនាំចេញទំនិញ ដែលមានចែងក្នុងប្រកាសលេខ ០៦០ MoC/M 2002 ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០២ :

ក- <u>ទំនិញនាំចេញតាមនាវា (By Sea) អាចនាំចេញបាន លុះត្រាមាន</u> :



Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 ( Kingdom of Cambodia )
Minister' s Mobile Phone (855-12) 821888 Facsimile: (855-23) 213288
Staff's Mobile Phones: (855-12) 818883 / 881223 Facsimile: (855-23) 426396

- របាយការណ៍របស់មន្ត្រីនាយកដ្ឋានជំនាញនៃក្រសួងពាណិជ្ជកម្ម និង ឧស្សាហកម្ម
- វិក័យប័ត្រទំនិញ (Invoice) ធ្វើដោយក្រុមហ៊ុន
- តារាងបញ្ជាក់ការវេចខ្ចប់ (Packing List) ធ្វើដោយក្រុមហ៊ុន

ខ- ទំនិញដែលបាននាំចេញរួចហើយតាមនាវា (By Sea) ក្រុមហ៊ុន ឬ រោងចក្រ អាចសុំយក :

- វិក័យប័ត្រពាណិជ្ជកម្ម (Commercial Invoice)
- វិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញ (Certificate of Origin)
- អាជ្ញាប័ណ្ណនាំចេញ (Export License)

លុះត្រាមានឯកសារយោងដូចខាងក្រោមនេះ :

- វិញ្ញាបនប័ត្របញ្ជាក់បរិមាណទំនិញ (Certificate of Quantity)
- ប្រតិវេទន៍គយ និង រដ្ឋាករ (Customs' Declaration)
- អាញ្ញាតិប័ណ្ណដឹកជញ្ជូន (Bill of Lading)
- វិញ្ញាបនប័ត្របញ្ជាក់ផលិតកម្ម (Certificate of Processing)

គ- ចំពោះទំនិញនាំចេញតាមយន្តហោះ (By Air) ក្រុមហ៊ុនត្រូវមានឯកសារភ្ជាប់ដូចខាងក្រោមនេះ :

- ឯកសារយោង (Airway Bill; Certificate of Quantity; Customs' Declaration) ដែលបាននាំចេញជើងមុន បន្ទាប់នៃការស្នើសុំថ្មី
- វិញ្ញាបនប័ត្របញ្ជាក់ផលិតកម្ម (Certificate of Processing)
- វិក័យប័ត្រទំនិញ (Invoice) ធ្វើដោយក្រុមហ៊ុន
- តារាងបញ្ជាក់ការវេចខ្ចប់ (Packing List) ធ្វើដោយក្រុមហ៊ុន
- កិច្ចសន្យាទិញ-លក់ (Sale Contract)
- ការបញ្ជាទិញ (Purchasing Order)

**ប្រការ ៧ :** នាយកខុទ្ទកាល័យ , អគ្គនាយកបច្ចេកទេស , អគ្គនាយករដ្ឋបាល និង ហិរញ្ញវត្ថុ , ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម , ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស , ប្រធាននាយកដ្ឋានកាំកុងត្រូល , ប្រធាននាយកដ្ឋានរដ្ឋបាល ត្រូវអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធិភាព ។

File: Prakas on Decentralized Procedure for remote Industrial Outlets

**ប្រការ ៨ ៖** ប្រកាស និង សេចក្តីជូនដំណឹង ដែលមានលក្ខណៈផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

**ចម្លងជូន ៖**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល
- ក្រសួងសង្គមកិច្ច-ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវៈនិតិសម្បទា
- ស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា
- គណៈប្រតិភូសហគមន៍អឺរ៉ុបប្រចាំទីក្រុងភ្នំពេញ
- សាលាខេត្តស្វាយរៀង
- សាលាខេត្តកំពង់ចាម
- សាលាខេត្តកំពង់ឆ្នាំង
- សាលាក្រុងព្រះសីហនុ
- សមាគមកាត់ដេរសំលៀកបំពាក់នៅកម្ពុជា
- សមាគមរោងចក្រស្បែកជើងនៅកម្ពុជា
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

File: Prakas on Decentralized Procedure for remote Industrial Outlets

Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 ( Kingdom of Cambodia )
Minister' s Mobile Phone (855-12) 821888 Facsimile: (855-23) 213288
Staff's Mobile Phones: (855-12) 818883 / 881223 Facsimile: (855-23) 426396

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## KINGDOM OF CAMBODIA

Nation - Religion - King

ក្រសួងពាណិជ្ជកម្ម

Ministry of Commerce

No. ២៦៨ MoC / M 2002

រាជធានីភ្នំពេញ.ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០២

# ប្រកាស

## ស្តីពីការតែងតាំងសមាជិកទីប្រឹក្សាសភាពាណិជ្ជកម្មរាជធានីភ្នំពេញ

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា .

- បានឃើញព្រះរាជក្រមលេខ ០២នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី .

- បានឃើញព្រះរាជក្រឹត្យ លេខនស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណា ចក្រកម្ពុជា .

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម

-បានឃើញព្រះរាជក្រមលេខ នស/រកស/០៦៩៥/០៣ ចុះថ្ងៃទី ២២. ០៦.១៩៩៥ ប្រកាសដែលអោយប្រើច្បាប់ស្តីពី សភាពាណិជ្ជកម្ម ។

- បានឃើញអនុក្រឹត្យ លេខ ៥៤ អនក្របក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម ។

-បានឃើញអនុក្រឹត្យលេខ ៤២៣ អនក្រ.តត ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០២ ស្តីពីការទទួលស្គាល់សមាជិកជ្រើសរើសតាំង និងសមាសភាពការិយាល័យប្រតិបត្តិ សំរាប់សភាពាណិជ្ជកម្មរាជធានីភ្នំពេញ អាណត្តិទី ២

## សំរេច

**ប្រការ ១** :តែងតាំង សមាជិកទីប្រឹក្សាសភាពាណិជ្ជកម្មរាជធានីភ្នំពេញ ចំនួន ១៩ រូប ៖-

១- លោក វ៉ាន់ សួអៀង
២- លោក យាំ ស៊ុយសាង
៣- លោក Tan Sri Dato Soon Siew Hoong
៤- លោក ជាសៀម ឡាយ
៥- លោកឧកញ៉ា ស្រី លោងឈាង
៦- លោក ស៊ីវ ថៃ
៧- លោក ជឿង ឆាណាយវ៉ា

| | | | |
|---|---|---|---|
| ៨- | លោក | ការ | សាវុត្ថ |
| ៩- | លោក | ចុម | គីមសុន |
| ១០- | លោក | ចាន់ | ហ៊ុយលួង |
| ១១- | លោក | តាន់ | ហាំងម៉េង |
| ១២- | លោក | តូនី | តាន់ឪហ្សុណូ |
| ១៣- | លោក | កុក | ហ្សាក់ |
| ១៤- | លោក | ផៃ | ហុកឈួន |
| ១៥- | លោក | អ៊ឹង | ហុងម៉េង |
| ១៦- | លោក | អៀ | ជៀមហេង |
| ១៧- | លោក | តាំង | ងួនសុង |
| ១៨- | លោក | ភីង | កាំង |
| ១៩- | លោក | ឧកញ៉ា | ដួង ឈីវ |

**ប្រការ ២** : អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេស អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធានសភាពាណិជ្ជកម្មរាជធានីភ្នំពេញ និង សាមីខ្លួន ត្រូវអនុវត្តប្រកាសនេះ ។

ព្រះរាជាណាចក្រកម្ពុជា រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចម_ប្រសិទ្ធ

**កន្លែងទទួល**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ដូចប្រការ២" ដើម្បីអនុវត្ត "
- ឯកសារ_កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

C.o b

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ : ៣៧៥ ប្រក.កសក

## ប្រកាស

## ស្តីពី

## ការអនុញ្ញាតអោយបង្កើតរោងសិប្បកម្មផលិតគ្រឿងសង្ហារិមកែច្នៃអំពីឈើក្នុងស្រុក របស់ក្រុមហ៊ុន សុខ ឆាយ អាហារ៉ណេ នីហារ៉ណេ

********

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត/១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញប្រកាសលេខ ០០៩២ ប្រក.កសក. ម ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ១៩៨៩ របស់ក្រសួងកសិកម្ម ស្តីពីការបង្កើត និងគ្រប់គ្រងរោងចក្រអារឈើ រោងចក្រកែច្នៃឈើ រោងអារឈើ រោងជាងឈើ សិប្បកម្មប្រើប្រាស់វត្ថុធាតុដើមជាផល- អនុផល ព្រៃឈើរបស់រដ្ឋ រដ្ឋចំរុះឯកជន សមូហភាព និងឯកជន ក្នុងទូទាំងរដ្ឋកម្ពុជា
- បានឃើញមតិយល់ព្រមរបស់ឯកឧត្តមអភិបាលខេត្តកណ្តាល តាមចំណារលេខ ៣៥២ សណ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០២ លើសំណើសុំបង្កើតសិប្បកម្មផលិតគ្រឿងសង្ហារិមកែច្នៃអំពីឈើក្នុងស្រុក របស់ក្រុមហ៊ុន សុង ឆាយ អាហារ៉ណេ នីហារ៉ណេ ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ២០០២
- តាមសំណើរបស់ប្រធាននាយកដ្ឋានរុក្ខា-ប្រមាញ់

## សំរេច

**ប្រការ១:** - អនុញ្ញាតអោយលោក **កៅ សុខ** ភេទប្រុស អាយុ ៣៣ ឆ្នាំ នាយកក្រុមហ៊ុន សុង ឆាយ អាហារ៉ណេ នីហារ៉ណេ បង្កើតរោង សិប្បកម្មផលិតគ្រឿងសង្ហារិមកែច្នៃអំពីឈើក្នុងស្រុក សំរាប់ធ្វើការនាំចេញទៅបរទេសដែលមាន :

- ទីតាំងនៅភូមិទួលតាចាន់ ឃុំទួលតាចាន់ ឃុំព្រៃកងង ស្រុកគៀនស្វាយ ខេត្តកណ្តាល ។

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Sangkat Tonle Basak Khan Chamkarmon B V D Phnom Penh, Cambodia
ទូរស័ព្ទលេខ : (០២៣) ២១១ ៣៥១/ ២១១ ៣៥២ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone (023) 211 351/211 352, Fax . (855) 23 - 217 320

C.o b

- ម៉ាស៊ីនចៀររឿងលធុនតូចប្រើដោយចរន្តអគ្គិសនី ចំនួន ០៦ គ្រឿង , ម៉ាស៊ីនខាត់រលីងប្រើដោយម៉ូទ័រ ចំនួន ០៥ គ្រឿង
- សមត្ថភាពផលិតក្នុងមួយឆ្នាំ ២០ ម៉ែត្រគីបគុណជាប្រភេទឈើក្នុងស្រុក (ខ្នុរ , ដើមចាន់ , ដើមអំពិលទឹកបារាំង និង ឈើសំបកកេសចាស់ៗ) ។

**ប្រការ២:** - សាមីជនដែលបានទទួលការអនុញ្ញាតអោយបង្កើតរោងសិប្បកម្ម ត្រូវប្រតិបត្តិតាមល័ក្ខខ័ណ្ឌនៃបទបញ្ជាដូចខាងក្រោម:

ក-ត្រូវសំរួលដល់មុខនាទីសមត្ថកិច្ចរុក្ខា-ប្រមាញ់ ចេញ-ចូល ធ្វើការត្រួតពិនិត្យសកម្មភាពរោងសិប្បកម្មគ្រប់ពេលវេលា ។

ខ- ផលិតផលឈើកែច្នៃដឹកជញ្ជូនចេញពីបរិវេណរោងសិប្បកម្ម ត្រូវមានលិខិតអនុញ្ញាតចេញដោយសមត្ថកិច្ចរុក្ខា-ប្រមាញ់ ។

គ- ត្រូវមានសៀវភៅបញ្ជីតាមដានឈើចេញ-ចូលរោងសិប្បកម្ម ។

ឃ- ត្រូវទទួលខុសត្រូវលើគ្រប់បទល្មើស ដែលកើតមានក្នុងបរិវេណរោងសិប្បកម្មរបស់ខ្លួន ។

ង- ការប្តូរឈ្មោះ ឬផ្ទេររោងសិប្បកម្មពីអ្នកគ្រប់គ្រងមួយ ទៅអ្នកគ្រប់គ្រងមួយទៀត ត្រូវហាមឃាត់ជាដាច់ខាត ។

**ប្រការ៣:** - ប្រកាសអនុញ្ញាតនេះត្រូវទុកជានិរាករណ៍ ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្នុងករណីដែលយល់ឃើញថាជាការចាំបាច់ ឬ បានប្រព្រឹត្តអំពើល្មើសធ្ងន់ធ្ងរ ។

**ប្រការ៤:** - អគ្គនាយកក្រសួង អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានផែនការ-ស្ថិតិ និងសហប្រតិបត្តិការអន្តរជាតិ ប្រធាននាយកដ្ឋាននីតិកម្ម កសិកម្ម ប្រធាននាយកដ្ឋានរុក្ខា-ប្រមាញ់ ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ប្រធានការិយាល័យរុក្ខា-ប្រមាញ់ខេត្តកណ្តាល និង សាមីជនត្រូវទទួលបន្ទុករៀង ៗខ្លួន អនុវត្តប្រកាសនេះ ។

**ប្រការ៥:** - ប្រកាសនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ [illegible] ឆ្នាំ ២០០២

រដ្ឋមន្ត្រី

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងបរិស្ថាន
- សាលាខេត្តកណ្តាល

  " ដើម្បីជូនជ្រាប "
- ដូចប្រការ៤ " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពត៌មាន**

លេខ ៧៩៥/០២ ព.ម (ស.ក)

រាជធានីភ្នំពេញ,ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០២

# ប្រកាស

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពត៌មាន

******

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣ ។
- បានឃើញព្រះរាជក្រឹត្យ ន.ស.រ.ក.ត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រមលេខ ន.ស.រ.ក.ម ០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពត៌មាន ។
- បានឃើញព្រះរាជក្រមលេខ នស/រកម ០៨៩៥-០៧ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥ ប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសារពត៌មាន ។
- បានឃើញអនុក្រឹត្យលេខ ៧០ អ.ន.ក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៥ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងពត៌មាន ។
- បានឃើញប្រកាសរបស់ក្រសួងពត៌មានលេខ ២៨៦ /៩៦ ព.មប្រក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ១៩៩៦ ស្តីពីការអនុញ្ញាតអោយកាសែត " សេរីភាពថ្មី " ដំណើរការបោះពុម្ពចែកផ្សាយដែលមានលោក សោម វីរៈ ជាចាងហ្វាងការផ្សាយ ។
- បានឃើញលិខិតរបស់លោក សោម វីរៈ ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០២ ស្តីពីសំណើសុំបន្តអាជ្ញាបណ្ណ័របស់កាសែត "សេរីភាពថ្មី " ។

## សម្រេច

**ប្រការ១ :** អនុញ្ញាតឱ្យកាសែត " **សេរីភាពថ្មី** " បន្តអាជ្ញាបណ្ណ័បោះពុម្ពចែកផ្សាយដោយមានលោក **សោម វីរៈ** ជាចាងហ្វាងការផ្សាយ។ ទីស្នាក់ការផ្ទះលេខ៣៤ ផ្លូវលេខ២១០ សង្កាត់ផ្សារទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

**ប្រការ២ :** ប្រកាសរបស់ក្រសួងពត៌មានលេខ ២៨៦/៩៦ ព.មប្រក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ ១៩៩ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៣ :** រាល់ដំណើរការបោះពុម្ពចែកផ្សាយ ត្រូវគោរពតាមច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីរបបសារពត៌មាន ក្រមសីលធម៌អ្នកសារពត៌មាន ។

**ប្រការ៤ :** ក្នុងករណីប្រព្រឹត្តល្មើសនឹងប្រការ ៣ ខាងលើ សាមីខ្លួនត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

**ប្រការ៥ :** អគ្គនាយករដ្ឋបាល និងសោតទស្សន៍ ប្រធាននាយកដ្ឋានមណ្ឌលពត៌មាននៃក្រសួងពត៌មាន និងចាងហ្វាងការផ្សាយកាសែត"**សេរីភាពថ្មី**" ត្រូវអនុវត្តនូវប្រកាសនេះ ។

**ប្រការ៦ :** ប្រកាសនេះមានប្រសិទ្ធភាពរយៈពេល១ឆ្នាំ ។ ក្នុងករណីមិនសុំបន្តអាយុកាលនៃអាជ្ញាប័ណ្ណលើសរយៈពេល៣ខែក្រសួងពត៌មាន ចាត់ទុកថា សាមីចាងហ្វាងបានបោះបង់អាជីវកម្មរបស់ខ្លួនជាស្ថាពរ ។

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**

**ចម្លងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យមេធាវីរាជរដ្ឋាភិបាល
- ក្រសួងមហាផ្ទៃ
- ក្រសួងយុត្តិធម៌
- អភិបាលរាជធានីភ្នំពេញ
- តុលាការរាជធានីភ្នំពេញ
- ស្នងការនគរបាលរាជធានីភ្នំពេញ
- គ្រប់សមាគមអ្នកសារពត៌មានកម្ពុជា "ដើម្បីជ្រាបជាពត៌មាន"
- សាមីខ្លួន